ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Oct-2015, 09:46
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥**

**ម៉ោង ០៩:២១នាទី**

**សវនាការលើកទី៣៣៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី

*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ត្រាវីស ហ្វារ

*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ (*Ms. Anta GUISSE*)

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

(*Mr Calvin SAUNDERS*)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍(*Ms.Marie GUIRAUD*)

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:២១:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ តាមគម្រោងដែលបានកំណត់កាលពីម្សិលមិញ អង្គជំនុំជម្រះបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី សុះ រំលី ហើយនិងគ្រោងនៅសាក្សីបម្រុងមួយរូបគឺ 2-TCW-996 ពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានការងារត្រពាំងថ្ម។ ប៉ុន្តែកាលពីម្សិលមិញ នៅពេលរសៀលចុងក្រោយ គឺលោកមេធាវីក្ដីលោក នួន ជា គឺលោកមេធាវី កូប៉េ បានលើកឡើងពីបញ្ហានៃការដែលកត់សម្គាល់ពីស្ថានភាពនៃទំនាស់ផលប្រយោជន៍រវាងសាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សី ដែលមានគិតទៅគឺថាវាអាចមានទំនាស់ផលប្រយោជន៍។ ហើយអង្គជំនុំជម្រះបានលើកបញ្ហានេះយកមកពិនិត្យពិចារណាតាំងពីម្សិលមិញ។ ហើយដោយសារបញ្ហានេះអង្គជំនុំជម្រះរកដោះស្រាយមិនទាន់បាននៅឡើយទេ ដោយមូលហេតុពីរ ទី១ លើបញ្ហាពិនិត្យលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងបញ្ហានេះ វាក្នុងកម្រិតមួយ គឺមិនទាន់បានជ្រះស្រឡះនៅឡើយនៅក្នុងចំណោមចៅក្រមនៃការពិភាក្សា។ ហើយបញ្ហាទី២ គឺមេធាវីប្រឹក្សាដទៃទៀតមានចំនួនបីនាក់ប៉ុន្តែខាងអង្គភាពគាំពារសាក្សីមិនអាចរកមេធាវីប្រឹក្សាមកជំនួសលោកមេធាវី ឌុច ផារី បានទេ។ ហើយទន្ទឹមនឹងនេះ ក៏កើតហេតុនូវបញ្ហាមួយទៀត ដោយការពិភាក្សាលើបញ្ហាដែលកើតមាននាពេលចុងក្រោយពាក់ព័ន្ធជាមួយនឹងភាគីបានយកឯកសារថ្មីៗដែលបានស្នើសុំដាក់ និងអង្គជំនុំជម្រះទទួលយកជាឯកសារភស្តុតាងពីសំណុំរឿង០០៣, ០០៤ ឥឡូវនេះឃើញថាវាកើតឡើងនូវបញ្ហាប្រឈមនឹងផ្នែកខាងកិច្ចការនីតិវិធីរបស់តុលាការ។ ហើយដោយហេតុផលទាំងពីរនេះ គឺនាំឲ្យអង្គជំនុំជម្រះមិនអាចស្ដាប់សក្ខីកម្មសាក្សី សុះ រំលី បាននៅថ្ងៃនេះទេ។

[០៩:២៤:៣៣]

ហើយទី២ គឺដូចគ្នាដែលអង្គជំនុំជម្រះគ្រោងស្ដាប់សក្ខីកម្មសាក្សី 2-TCW-996 គឺគាត់មានស្ថានភាពដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នានឹងសាក្សី សុះ រំលី ដែរ ដោយគាត់គឺមានមេធាវីប្រឹក្សា គឺលោកមេធាវី ឌុច ផារី។ ហើយទី២គឺបញ្ហាប្រឈមចំពោះមុខដែលអង្គជំនុំជម្រះត្រូវពិភាក្សា

ដោះស្រាយនោះ គឺដោយសារផលប៉ះពាល់ទាំងឡាយ ដែលកើតចេញពីការដែលភាគីតែងតែពិនិត្យលទ្ធភាពនៅក្នុងការលើកយកនូវឯកសារថ្មីៗផ្សេងៗទៀត ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកយកពីសំណុំរឿង ០០៣, ០០៤ យកមកដាក់បង្ហាញ ហើយភាគីពាក់ព័ន្ធបានស្នើសុំដាក់ ឬក៏អង្គជំនុំជម្រះបានទទួលយកជាឯកសារភស្តុតាងដេញដោល។ ដោយសារហេតុផលពីរនេះដូចគ្នា ហេតុដូច្នេះសាក្សី 2-TCW-996 ក៏អង្គជំនុំជម្រះមិនអាចធ្វើសវនាការស្តាប់សក្ខីកម្មរបស់គាត់នៅថ្ងៃស្អែកនេះបានដែរ។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថាការស្តាប់សក្ខីកម្មសាក្សីទាំងពីររូបគឺ សុះ រំលី ហើយនិងសាក្សី TCW-996 នេះអង្គជំនុំជម្រះលើកទៅធ្វើសវនាការស្តាប់សក្ខីកម្មរបស់គាត់នៅក្រោយពេលភ្ជុំបិណ្ឌ តាមកម្មវិធីជាក់ស្តែងដែលអង្គជំនុំជម្រះនឹងពិគ្រោះយោបល់ ពិភាក្សាជាមួយនឹងអង្គភាពវេស្ស អំពីលទ្ធភាព ថាតើសាក្សីរូបនេះអាចមកផ្តល់សក្ខីកម្មបាននៅពេលណា។ ហេតុដូច្នេះគឺអង្គជំនុំជម្រះជម្រាបជូនភាគី និងសាធារណជនដូច្នេះថា អង្គជំនុំជម្រះមិនអាចធ្វើសវនាការស្តាប់ បន្តស្តាប់សក្ខីកម្ម សាក្សី សុះ រំលី ហើយនិងសាក្សី 2-TCW-996 បានទេ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សីទាំងពីររូប សាក្សី សុះ រំលី និងសាក្សីបម្រុងនេះត្រឡប់ទៅកាន់លំនៅឋានរបស់គាត់ទៅវិញចុះ។

បាទ សូមអញ្ជើញមានបញ្ហាអ្វីទេ?

បាទ ដោយសារបញ្ហាខ្លី ខ្ញុំមិនទាន់សម្រេចលើសំណើសុំរបស់ នួន ជា ទេ ដូចទំនងជាមិនអាចបន្តសវនាការដូចតែដូចទេ។ អ៊ីចឹងយើងមិនទាន់សម្រេចទេ សូមអញ្ជើញចាំស្តាប់ភាគីសិន។ បាទ សូមអញ្ជើញមេធាវីការពាក្តីលោក នួន ជា -- លោក ខៀវ សំផន!

[០៩:២៧:៥៧]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនយល់ថាតើលោកប្រធានចង់និយាយអំពីបញ្ហាវត្តមានរបស់ នួន ជា សិន ឬក៏យ៉ាងម៉េច ឬក៏ឲ្យខ្ញុំធ្វើការសង្កេតសិន ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថាមិនចាំបាច់ទេ សូមឲ្យនិយាយតែម្តងទៅ ខ្ញុំយល់ថា ដំណើរការសវនាការអង្គហេតុហ្នឹង វាអត់មានទេ អ៊ីចឹងសូម អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីនិយាយតែម្តងទៅ ហើយបញ្ហាអីដូចជាខ្លីទេ ខ្ញុំមើលទៅវា -- មើលៗការបកប្រែភាសាដូចជាមានបញ្ហា ខាងការបកប្រែភាសា។

បាទ ខ្ញុំជម្រាបអំមិញហើយ ខ្ញុំប្រមើលមើលទៅ ការដំណើរការសវនាការលើអង្គសេចក្តីហ្នឹង គឺ អត់មានទេ ហើយអំឡុងពេលនៃពិភាក្សា នៅព្រឹកនេះទំនងជារយៈពេលខ្លីទេ អ៊ីចឹងខ្ញុំមិនចាំបាច់សម្រេចលើសំណើសុំរបស់លោក នួន ជា ទេ។ ហើយខ្ញុំចង់ស្តាប់នូវៗមតិយោបល់ ឬសំណើសុំរបស់ភាគី ជាពិសេសមេធាវីការពារក្តីលើបញ្ហាផ្សេងៗដែលកើតមាន ដែលមានបំណងលើកឡើងដើម្បីអង្គជំនុំជម្រះ យកបញ្ហាទាំងអស់នោះគួបផ្សំនឹងបញ្ហាដែលកើតមានកន្លងមកនេះ យកទៅពិភាក្សាសម្រេច និងផ្សព្វផ្សាយជូនភាគីនៅពេលក្រោយ។ ប្រសិនបើមានសូមអញ្ជើញបាទ!

[០៩:២៩:២៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមនិយាយបន្តអំពីការសង្កេតរបស់ខ្ញុំដែលខ្ញុំបានធ្វើកាលពីប៉ុន្មានថ្ងៃមុន ពាក់ព័ន្ធទៅនឹងការរៀបចំខ្លួនរបស់មេធាវីការពារក្តី សម្រាប់សវនាការលើបណ្តឹងសាទុក្ខ។ កាលពីម្សិលមិញ យើងទទួលបានព័ត៌មានថ្មីអំពីតុលាការកំពូល ពីព្រោះមានការបញ្ជាក់ថា សវនាការហ្នឹង គឺកំណត់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែវិច្ឆិកា។ ដូច្នេះ នៅតែមានលទ្ធភាពដដែល ក្នុងការសួរសាក្សីមុននឹងកាលបរិច្ឆេទកំណត់នេះ។ ដូច្នេះខ្ញុំនៅតែលើកសំណើរបស់ខ្ញុំដដែល ដែលទោះបីជាគិតថាវាលឿនពេកក៏ដោយ គឺថាសុំលទ្ធភាពយ៉ាងម៉េចកុំឲ្យមានសវនាការនៅក្នុងពេលត្រៀមរៀបចំខ្លួនសម្រាប់សវនាការលើបណ្តឹងសាទុក្ខរបស់តុលាការកំពូលនេះ។

ជាដំបូងនោះ គឺយើងបានស្នើសុំរយៈពេល៥សប្តាហ៍សម្រាប់ត្រៀមខ្លួនមុនពេលសវនាការលើបណ្តឹងសាទុក្ខ ដោយយើងមិនបានដឹងជាមុនអំពីកម្មវិធីរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងការកោះហៅសាក្សីនោះទេ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ យើងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកុំរៀបចំសវនាការអី ក្រោយ

ពេលបុណ្យភ្ជុំបិណ្ឌហ្នឹង ចាំឲ្យតុលាការកំពូលបើកសវនាការចប់សិន គឺក្រោយថ្ងៃ១៨ វិច្ឆិកា ចាំអង្គជំនុំជម្រះសាលាដំបូងគ្រោងកោះហៅសាក្សីមកធ្វើសវនាការលើសំណុំរឿង ០០២/០២ យើងនេះ។ ដូច្នេះផ្អែកតាមព័ត៌មានដែលយើងទទួលបាន គឺច្បាស់ណាស់ថា ពេលវេលាចាំបាច់នៃការត្រៀមរៀបចំខ្លួនហ្នឹង មិនមែនជាពេលយើងឈប់សម្រាកទេ។ វាជាពេលវេលាមួយដែលត្រៀមប្រឈមនឹងបញ្ហាផ្សេងៗ។ ដូច្នេះសូមឲ្យយើងទទួលបានពេលវេលាដើម្បីឲ្យយើងអាចធ្វើការទៅលើធាតុផ្សំផ្សេងៗទៀត ដែលអាចឲ្យយើងធ្វើយ៉ាងម៉េចបន្តសវនាការយើងនៅពេលក្រោយទៀត។ ដូច្នេះជារួម សំណើរបស់យើង គឺសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកុំគ្រោងសវនាការអី នៅមុនថ្ងៃ១៨ វិច្ឆិកានោះ គឺសុំឲ្យតុលាការកំពូលរៀបចំសវនាការលើបណ្ដឹងសាទុក្ខចប់សិន ទើបសាលាដំបូងរៀបចំសវនាការបន្តទៅទៀត។

[០៩:៣២:១៧]

**ប្រធានអង្គជំនុំ៖**

ចុះក្រុមភាគីដទៃទៀត មានបញ្ហាអីទេ?

លោក វ៉ិចទ័រ កូប៉េ អញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ យើងយល់ស្របជាមួយនឹងសំណើរបស់មេធាវី ខៀវ សំផន។ ប៉ុន្តែយើងមានករណីលើកលែងបន្តិច ព្រោះថាវាពាក់ព័ន្ធទៅនឹងសក្ខីកម្មនៃបណ្ដឹងឧទ្ធរណ៍សាក្សី 996។ ហើយយើងស្នើសុំសាក្សីនេះ ប៉ុន្តែមិនអាចមកនៅថ្ងៃស្អែកនោះទេ។ ហើយដូច្នេះយើងចង់ឲ្យមានការស្ដាប់សក្ខីកម្មទៅលើសាក្សីនេះ។ ចំពោះយើងគឺសំខាន់ណាស់ដែលថាសាក្សី 991 ត្រូវមកផ្ដល់សក្ខីកម្មនៅមុនពេលសក្ខីកម្ម -- មុនពេលសវនាការរបស់អង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះយើងស្នើសុំពិសេសតែចំពោះសាក្សី 996 នេះប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:៣៣:៣៣]

**លោក នីកូឡាស គូមជែន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ មុនពេលដែលបញ្ហានេះលើកឡើង គឺយើងបញ្ជាក់ថា បញ្ហានេះហាក់បីដូចជាឆាប់រហ័សពេក។ ប៉ុន្តែឥឡូវនេះ យើងទទួលបានការបញ្ជាក់ពីពេលវេលា ក៏ដូចជាកាលវិភាគដែលអង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើសវនាការ គឺមានរយៈពេល៣ថ្ងៃ។ ដូច្នេះ ខ្ញុំគិតថាវាជាការសំខាន់ ដើម្បីឲ្យភាគីទាំងអស់អាចត្រៀមខ្លួនរៀបចំសវនាការនេះ។ ប៉ុន្តែដោយសារតែបណ្តឹងសាទុក្ខនឹងចាប់ផ្តើមនៅពេលខាងមុខនេះ ដូច្នេះខ្ញុំគិតថាបណ្តឹងសាទុក្ខគឺបានធ្វើតាំងពីខែមីនា, មេសា មកម្ល៉េះឆ្នាំនេះ។ ហេតុដូច្នេះ យើងខ្ញុំស្នើសុំឲ្យមានពេលវេលា ហោចណាស់ក៏មួយសប្តាហ៍ដើម្បីត្រៀមខ្លួនទៅលើបណ្តឹងសាទុក្ខ ទៅលើសវនាការបណ្តឹងសាទុក្ខ។ ចំពោះសាក្សីដែលត្រូវកោះហៅដោយតុលាការកំពូល យើងមិនប្រាកដថាយ៉ាងដូចម្តេចនោះទេ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះមិនមានសាក្សីណាបន្ថែមទៀត -- សុំទោស ខ្ញុំមើលឯកសារ គឺថានៅក្នុងខែវិច្ឆិកា ប្រសិនបើសវនាការ ត្រូវបានបញ្ចប់នៅថ្ងៃ០៥ ខែវិច្ឆិកា ដូច្នេះភាគីទាំងអស់គឺមានរយៈពេល១១ថ្ងៃ ដើម្បីត្រៀមខ្លួនទៅលើបណ្តឹងសាទុក្ខ។ ហើយនេះគឺជាពេលវេលាដែលយើងត្រូវត្រៀមខ្លួន ហើយយើងមិនទាន់គិតដល់សាក្សីដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងកោះហៅផង។

ដូច្នេះ កាលដែលមេធាវីការពារក្តីស្នើសុំឲ្យមានការផ្អាកនៅពេលឥឡូវនេះ គឺផ្អាកការស្តាប់សក្ខីកម្មសាក្សីនេះ ឬក៏អាចផ្អាកការឈប់សម្រាកនៅពេលក្រោយបុណ្យចូលឆ្នាំហ្នឹង ខ្ញុំគិតថាយើងនឹងមានពេលវេលាមួយ ហើយខ្ញុំគិតថា យើងអាចបែងចែកពេលវេលាជាមួយតុលាការកំពូល។ ដូច្នេះ ភាគីអាចមានពេលវេលាមួយថ្ងៃកន្លះដើម្បីត្រៀម ប៉ុន្តែចំពោះយើងខ្ញុំគិតថា ១១ថ្ងៃគឺគ្រប់គ្រាន់ហើយ ប៉ុន្តែយើងស្នើសុំថា ការស្នើសុំប្រាំ ឬប្រាំមួយសប្តាហ៍វាហាក់ដូចជាហួសហេតុពេក ហើយវាជាការទាមទារមិនសមហេតុផលសម្រាប់តុលាការនេះ។ ហើយខ្ញុំគិតថា ខាងសហព្រះរាជអាជ្ញាជាតិគឺលោកជំទាវ ជា លាង តាមរយៈសហការីរបស់គាត់ អាចនឹងមានការបញ្ចេញមតិយោបល់អ្វីបន្ថែមទៀត។ ចំពោះខ្ញុំ ខ្ញុំសូមបញ្ជាក់ថា ខាងព្រះរាជអាជ្ញាត្រូវត្រៀមខ្លួនសម្រាប់បណ្តឹងសាទុក្ខទាំងពីរនេះទៀត គឺថា យើងត្រូវត្រៀមខ្លួនឆ្លើយទៅនឹងមូលដ្ឋាន ២២៧ របស់ខាង នួន ជា ហើយខាង ខៀវ សំផន

ប្រហែលជា ២០០ មូលដ្ឋានទៀត។ ដូច្នេះ ខ្ញុំគិតថាចំពោះព្រះរាជអាជ្ញាគឺ១១ថ្ងៃ គឺគ្រប់គ្រាន់ណាស់ទៅហើយ។

[០៩:៣៦:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ចំពោះសហព្រះរាជអាជ្ញាជាតិឯកភាពទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយអ្វីដែលយើងចង់បញ្ជាក់ជំហររបស់ខាងសហព្រះរាជអាជ្ញាជាតិគឺ យើងស្នើសុំឱ្យមានសវនាការនៅលើសំណុំរឿង០២/០២នេះ តាមដែលលទ្ធភាពច្រើនបំផុតដែលអាចធ្វើទៅបាន ហើយរយៈពេលសម្រាប់ត្រៀមសវនាការនៅលើបណ្ដឹងឧទ្ធរណ៍នោះ យើងខ្ញុំគិតថា រយៈពេលដែលស្នើសុំឱ្យសម្រាកបន្ទាប់ពីភ្ជុំបិណ្ឌហើយរហូតទៅដល់ថ្ងៃទី១៦ ខែវិច្ឆិកានោះ ហាក់ដូចជារយៈពេលយូរពេក វាប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃសវនាការសំណុំរឿង០២/០២ យ៉ាងយូរ។ ហេតុដូច្នេះ យើងខ្ញុំគិតថារយៈពេលមួយសប្ដាហ៍សម្រាប់ត្រៀមសវនាការលើបណ្ដឹងឧទ្ធរណ៍ ហាក់ដូចជាសមរម្យល្មមសម្រាប់សវនាការដែលមានរយៈពេល៣ថ្ងៃ។ អ៊ីចឹង ខ្ញុំសូមអរគុណលោកប្រធាន។

[០៩:៣៨:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំមានការកត់សម្គាល់ខ្លី ដើម្បីផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើម្បីឲ្យអង្គជំនុំជម្រះរក្សាតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ នៅពេលដែលអង្គជំនុំជម្រះសម្រេចទៅលើសំណើសុំរបស់មេធាវីការពារក្ដីលោក ខៀវ សំផន។

ខ្ញុំចង់រំឭកជូនអង្គជំនុំជម្រះអំពីវិធាន១០៩ ដែលគ្រប់គ្រងលើសវនាការបណ្ដឹងសាទុក្ខ។ តាមរយៈវិធាននោះ មេធាវីការពារក្ដីត្រូវតែធ្វើការថ្លែងដោយខ្លីអំពីមធ្យោបាយបណ្ដឹងសាទុក្ខរបស់ខ្លួន។ ដូច្នេះ ពួកគាត់ត្រូវតែជ្រើសរើសយកមូលដ្ឋាននៃបណ្ដឹងសាទុក្ខហ្នឹង ដែលខ្លួនបានសរសេរហើយយកមកធ្វើជាលាយលក្ខណ៍អក្សរ។ ដូច្នេះ មិនមានការស្នើសុំឲ្យស្វែងរកមូលដ្ឋានថ្មី ឬក៏រកយុទ្ធសាស្ត្រថ្មីអីទេ គឺគ្រាន់តែដកចេញពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួន នូវចំណុចដែលខ្លួនបានសរសេរហ្នឹង យកមកលើកឡើងជាផ្ទាល់មាត់តែប៉ុណ្ណោះ។

[០៩:៣៩:៣១]

ដូច្នេះពាក្យថា សង្ខេបនោះគឺមានបញ្ជាក់នៅក្នុងវិធាន១០៩ នៃវិធានផ្ទៃក្នុងរបស់យើង។ អ៊ីចឹង មេធាវីការពារក្ដីគ្រាន់តែធ្វើការបង្ហាញជាផ្ទាល់មាត់នូវអ្វីដែលខ្លួនបានសរសេររួចមកហើយ។ ខាងយើងក៏យើងធ្វើការសង្ខេបឆ្លើយតបដូចគ្នាដែរ ហើយជាចុងក្រោយមេធាវីការពារក្ដីក៏ឆ្លើយតបដោយសង្ខេបដែរ។ ដូច្នេះ នៅចំពោះមុខតុលាការកំពូល នេះគឺជានីតិវិធីជាលាយលក្ខណ៍អក្សរ ហើយមេធាវីការពារក្ដីមិនអាចបង្ហាញទឡ្ហីករណ៍ថ្មី ឬក៏បង្ហាញយុទ្ធសាស្ត្រថ្មីទេ។ ដូច្នេះ ខ្ញុំចោទសួរខ្លួនឯងអំពីសំណើរបស់មេធាវី កូប៉េ ក្នុងការស្ដាប់សាក្សី TCW-996 នេះ ជាសាក្សីនៃសំណុំរឿង00២/0២។ ដូច្នេះ វាជាសំណុំរឿងផ្សេងគ្នា ហើយមេធាវីការពារក្ដី នួន ជា មិនអាចប្រើប្រាស់សក្ខីកម្មរបស់សាក្សី 2-TCW-996 ដើម្បីមកកែប្រែមធ្យោបាយបណ្ដឹងសាទុក្ខរបស់ខ្លួន ដែលខ្លួនបានរៀបចំរួចមកហើយនោះទេ។

ខ្ញុំសូមលើកឡើងផងដែរ នូវបញ្ហាកាលបរិច្ឆេទ សហព្រះរាជអាជ្ញាបានឆ្លើយតបរួចមកហើយ ទៅនឹងសារណារបស់មេធាវីការពារក្ដី កាលពីថ្ងៃទី២៤ មេសា ហើយយើងបានឆ្លើយតបនៅថ្ងៃទី២៥ ឧសភា ដោយមានការបកប្រែជាភាសាខ្មែរនៅថ្ងៃទី១៦ កក្កដា។ ដូច្នេះ មេធាវីការពារក្ដីបានដឹងច្បាស់អំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា ហើយនិងរបស់ខាងសហមេធាវីនាំមុខ។

[០៩:៤១:២១]

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះគិតទៅលើបញ្ហាទាំងអស់នេះ នៅពេលដែលអង្គជំនុំជម្រះសម្រេចទៅលើសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ហើយដោយមានការគាំទ្រពីមេធាវី នួន ជា។ យើងបាននិយាយតាំងពីដំបូងហើយ ធ្វើយ៉ាងម៉េចឲ្យសំណុំរឿង០០២/០២ វិវត្តន៍ទៅមុខឲ្យបានរលូនតាមដែលអាចធ្វើទៅបាន។ ហើយខ្ញុំសូមឆ្លើយតបទៅនឹងការកត់សម្គាល់ចុងក្រោយរបស់មេធាវីការពារក្តី គឺចំណុចពីរ ទី១ យើងអាចឈប់សម្រាកដើម្បីឲ្យភាគីត្រៀមខ្លួនបណ្តឹងសាទុក្ខ។ មួយទៀតអង្គជំនុំជម្រះ អាចប្រើប្រាស់ឱកាសនេះ ដើម្បីឲ្យភាគីអាចដឹងច្បាស់អំពីឯកសារនានា ដែលនឹងត្រូវដាក់បង្ហាញ នាពេលខាងមុខ ហើយដែលវាមានសំខាន់សម្រាប់វគ្គបន្ទាប់ទៀតនៃសវនាការរបស់យើងនេះ។ ប្រសិនបើជាករណីនោះមែន យើងក៏មានផលប្រយោជន៍ដែរ។ យើងចង់ឲ្យភាគីទាំងអស់មានពេលវេលា គ្រប់គ្រាន់ដើម្បីពិនិត្យមើលឯកសារដែលពាក់ព័ន្ធសម្រាប់វគ្គសវនាការបន្ទាប់មកទៀត។ ដូច្នេះ ខ្ញុំគិតថា វាមានប្រយោជន៍សម្រាប់ភាគីទាំងអស់ ក្នុងការទទួលបានព័ត៌មានអំពីការបង្ហាញឯកសារនាពេលខាង មុខបន្ថែមទៀត ដែលអាចមានផលប៉ះពាល់ទៅលើវគ្គសវនាការ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម ហើយនិង ស-២១ ដើម្បីឲ្យអង្គជំនុំជម្រះអាចមានព័ត៌មានទាំងអស់ ដើម្បីអាចសម្រេចបានទៅលើការផ្អាក សវនាការតទៅ ឬក៏យ៉ាងម៉េច ក្នុងសំណុំរឿង០០២/០២ យើងនេះ។ ការផ្អាកនេះ គឺមានគោលបំណងពីរ។ ទី១ គឺទុកពេលវេលាឲ្យភាគីត្រៀមរៀបចំខ្លួនសម្រាប់សវនាការផ្ទាល់មាត់លើបណ្តឹងសាទុក្ខ ហើយ និងមួយទៀត ជាការផ្តល់ឱកាសឲ្យភាគីបានពិនិត្យមើល ឯកសារដែលមានភាពពាក់ព័ន្ធសម្រាប់ផ្នែកសវនាការពាក់ព័ន្ធនាពេលខាងមុខបន្តទៅទៀត។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមកត់សម្គាល់ខ្លី។

[០៩:៤៣:៣៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអន្តរាគមន៍មុនមេធាវី អង់តា ហ្គីសសេ ពីព្រោះថាខ្ញុំមានសំណួរដែលត្រូវសួរ។ លោកស្រីមេធាវី អង់តា ហ្គីសសេ លោកស្រីបានស្នើសុំកាលពីមុននោះ គឺ៥សប្តាហ៍សម្រាប់ត្រៀម

រៀបចំខ្លួនលើសវនាការបណ្តឹងសាទុក្ខ។ នៅពេលនោះ ប្រសិនបើខ្ញុំចាំមិនច្រឡំទេ លោកស្រីបានបញ្ជាក់ថា គឺមានការគ្រោងរយៈពេលជាង១០ថ្ងៃ សម្រាប់សវនាការលើបណ្តឹងសាទុក្ខ។ ក៏ប៉ុន្តែអ្វីដែលយើងដឹងនៅថ្ងៃនេះ គឺសវនាការលើបណ្តឹងសាទុក្ខហ្នឹង គឺមានរយៈពេលតែ៣ថ្ងៃទេ។ ដូច្នេះលោកស្រីដឹងអំពីការប្រែប្រួលនេះឬក៏អត់? ហើយលោកស្រីមានមូលដ្ឋានអីដើម្បីមកសុំរយៈពេល៥សប្តាហ៍នេះ? គឺថាវាមានភាពខុសគ្នាណាស់ ពីព្រោះពីមុនលោកស្រីគ្រោងថា មានរយៈពេលជាង១០ថ្ងៃ ឥឡូវមានតែ៣ថ្ងៃទេ នៃសវនាការលើបណ្តឹងសាទុក្ខនោះ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមឆ្លើយតប។ ខ្ញុំនិយាយនេះ គឺពាក់ព័ន្ធនឹងការរៀបចំខ្លួន។ ដូចខ្ញុំបានប្រាប់ពីមុនហើយ ថាយើងអត់ដឹងមុនទេ ថាតើសវនាការលើបណ្តឹងសាទុក្ខហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃ ហើយមានសាក្សីប៉ុន្មានដែលត្រូវកោះហៅនៅក្នុងតុលាការកំពូលនោះ។ អ៊ីចឹងហើយបានជាពេលនុ៎ងនោះ នៅពេលដែលខ្ញុំធ្វើសំណើ បានជាខ្ញុំសុំបែបនេះនោះ។ ហើយប្រសិនបើមានព័ត៌មានថ្មី ខ្ញុំអាចកែប្រែសំណើរបស់ខ្ញុំបាន។ អ៊ីចឹងខ្ញុំសុំហ្នឹង គឺថាធ្វើយ៉ាងម៉េច ដើម្បីកុំឲ្យថាវាត្រូវកែប្រែបន្តទៅទៀត។ ថ្ងៃនេះហ្នឹងខ្ញុំមិនដឹងថា តើមានសាក្សីត្រូវបានកោះហៅ ឬក៏អត់ទេ។ អ៊ីចឹងហើយបានជាខ្ញុំស្នើសុំឲ្យមានពេលច្រើន គឺធ្វើយ៉ាងម៉េចដើម្បីឲ្យយើងអាចរៀបចំខ្លួនបានល្អសម្រាប់តុលាការកំពូល។

នេះជាចំណុចទី១ ដែលខ្ញុំឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម។

[០៩:៤៥:៣៥]

ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងសាលសវនាការនេះ ខាងមេធាវីការពារក្តី នៅពេលដែលយើងមានការត្រៀមរៀបចំសម្រាប់សាក្សីនោះ គឺមានតែមេធាវីដដែលៗទេ ដែលជាអ្នកមកសួរសាក្សីនោះ។ ចំពោះខ្ញុំ គឺមានលោក អាកទួរ វ៉ែកគែន ហើយនិងខ្ញុំ គឺយើងបែងចែកការងារគ្នា។ ទោះបីជារៀបចំសវនាការលើបណ្តឹងសាទុក្ខ ឬក៏រៀបចំសវនាការនៃសំណុំរឿងយើងនេះ គឺយើងមានតែមេធាវីដដែលៗទេ ហើយក៏ប៉ុន្តែខាងម្ខាងទៀតនោះ យើងមានមេធាវីច្រើន ទោះបីជាសហមេធាវីនាំមុខដដែលក៏ដោយ ក៏ប៉ុន្តែពួកគាត់មានសហមេធាវីមកជួយសួរសាក្សី។ អ៊ីចឹងពួកគាត់មានគ្នាច្រើន ហើយសហព្រះរាជអាជ្ញានុ៎ង គាត់មានភារកិច្ចច្រើន ក៏ប៉ុន្តែគាត់ផ្លាស់វេនគ្នា

មានសហព្រះរាជអាជ្ញារង មានអីអ៊ីចឹងច្រើនផ្លាស់វេនគ្នាមកសួរនាំ។ ក៏ប៉ុន្តែយើង យើងអត់ស្ថិតនៅក្នុងស្ថានភាពដូចគ្នាទេ ចំពោះការរៀបចំការងារយើងនោះ គឺសម្រាប់ សំណុំរឿង០០២/០២ ឬក៏ការត្រៀមរៀបចំសម្រាប់សវនាការលើបណ្ដឹងសាទុក្ខយើងមានគ្នា តែដដែលទេ។

ចំពោះការលើកឡើងថា យើងនឹងនិយាយខ្លីនៅតុលាការកំពូល គឺពិតហើយ គឺយើងនិយាយដោយខ្លីទេ គឺយើងនឹងបង្ហាញទឡ្ហីករណ៍ ក៏ប៉ុន្តែនៅពេលដែលយើងត្រូវធ្វើការជ្រើសរើសនោះ គឺយើងត្រូវតែសម្រេចចិត្តឲ្យបានច្បាស់។ យើងត្រូវតែពិនិត្យមើលលើសារណាជាលាយលក្ខណ៍អក្សររបស់យើងទាំងអស់ឡើងវិញដើម្បីរកមូលដ្ឋាន ដើម្បីមកការពារកូនក្ដីរបស់យើងនៅចំពោះមុខតុលាការកំពូល គឺវាត្រូវការពេលច្រើន។ ប្រហែលជាយើងទាំងអស់គ្នាមិនដឹងច្បាស់អំពីការងាររបស់យើង ឬក៏របស់ផ្នែកផ្សេង មុនពេលដែលយើងចូលមកដល់សាលសវនាការទេ ក៏ប៉ុន្តែយោងទៅតាមបញ្ហាប្រឈម ហើយនិងផលប៉ះពាល់ផ្សេងៗនៃសេចក្ដីសម្រេចរបស់តុលាការកំពូលមកលើលោក ខៀវ សំផន ហើយ និងផលប៉ះពាល់នៃសំណុំរឿង០០២/០២ នោះ គឺថាយើងត្រូវតែធ្វើយ៉ាងម៉េចរៀបចំខ្លួនឲ្យបានល្អ ដើម្បីឲ្យយើងអាចធ្វើការបានល្អនៅចំពោះមុខតុលាការកំពូល។

[០៩:៤៨:០៧]

ទោះបីជាព្រះរាជអាជ្ញា ឬក៏មេធាវីនាំមុខគិតថា មិនត្រូវការពេលច្រើន ដោយសារតែខ្លួនមានវិធីសាស្ត្ររៀបចំខ្លួនបានល្អ ឬក៏មានបុគ្គលិកច្រើន គឺជាជម្រើសរបស់ពួកគាត់។ ក៏ប៉ុន្តែពួកយើងខាងយើងនេះ ខាងមេធាវីការពារក្ដីលោក ខៀវ សំផន យើងគិតថា យើងត្រូវការពេលច្រើនដើម្បីឲ្យយើងអាចធ្វើការងារយើងឲ្យបានល្អនៅចំពោះមុខតុលាការកំពូល។ ហើយ១១ថ្ងៃ ដូចដែលលើកដោយសហព្រះរាជអាជ្ញាហ្នឹង គឺវាមិនគ្រប់គ្រាន់ទេ សម្រាប់ខាងពួកយើង។ អ្នកផ្សេងគេគិតថា ពេលហ្នឹងសមស្របសម្រាប់ពួកគេ គឺស្រេចតែគេទៅ ក៏ប៉ុន្តែពួកយើង គឺយើងគិតថាមិនអាចធ្វើអ៊ីចឹងបានទេ។ យើងមិនអាចបំពេញចិត្តទាំងអស់គ្នាបានថា អ្នកណាចង់បានអ៊ីចេះ អ្នកណាចង់បានអ៊ីចេះទេ។ យើង គឺយើងត្រូវធ្វើយ៉ាងម៉េច ធ្វើការយើងឲ្យបានល្អ ការពារកូនក្ដីរបស់ខ្ញុំឲ្យបានល្អ។ ដូច្នេះខ្ញុំគិតថា ខ្ញុំត្រូវការពេលវេលាគ្រប់គ្រាន់ដើម្បី

ឲ្យខ្ញុំអាចបំពេញមុខងាររបស់ខ្ញុំបាន។ នេះជាអ្វីដែលយើងត្រូវការសម្រាប់មេធាវីការពារក្ដី យើងត្រូវតែធ្វើការយ៉ាងម៉េចក្នុងលក្ខខណ្ឌត្រឹមត្រូវ ហើយទោះបីជាមានអ្នកណាប្រកែកតវ៉ាយ៉ាងម៉េច គឺយើងមិនដឹងទេ។ យើងសុំនេះ គឺដើម្បីការងាររបស់យើង។

[០៩:៤៩:១៣]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លះៗដែរ គឺថាអាចដែលថាតុលាការកំពូលនឹងកោះហៅសាក្សីមួយចំនួន។ ហើយឥឡូវនេះ យើងមានសំណើសុំកោះហៅសាក្សីចំនួន១៣សំណើដែលកំពុងរង់ចាំ ហើយមានការស៊ើបអង្កេតក្នុងនាមតុលាការកំពូលបានធ្វើឡើងរួចទៅហើយ ហើយយើងរង់ចាំរហូតទៅដល់សប្ដាហ៍ថ្ងៃ០៩ ថ្ងៃ១០ ខែវិច្ឆិកា ហើយសង្ឃឹមថា នៅពេលនោះនឹងមានសាក្សីមកផ្ដល់សក្ខីកម្ម។

ចំណុចទី២ របស់ខ្ញុំ គឺថាខ្ញុំយល់ស្របជាមួយនឹងមេធាវី ខៀវ សំផន ចំពោះការបែងចែកការងារធ្វើការនៅតុលាការនេះ គឺថាដូចដែលខ្ញុំពិភាក្សាជាមួយសហការីជាតិរបស់ខ្ញុំ ខ្ញុំដឹងថាសហព្រះរាជអាជ្ញាម្នាក់មានមេធាវីប្រហែលជាប្រាំពីរនាក់មកធ្វើការជារៀងរាល់ថ្ងៃ។ ដូច្នេះចំពោះយើង ប្រសិនបើយើងអាចមានមេធាវីច្រើនមកធ្វើការ វាជាការល្អ។ ហើយការកត់សម្គាល់ចុងក្រោយរបស់ខ្ញុំមួយទៀត ចំពោះមូលដ្ឋានបណ្ដឹងសាទុក្ខ២២៧ ឬក៏មូលដ្ឋានបណ្ដឹងសាទុក្ខ២២៣ គឺវានៅតែជាបណ្ដឹងសាទុក្ខតែមួយ។ ដូច្នេះទោះបីដាក់តែមូលដ្ឋានតែមួយ ក៏វាជាបណ្ដឹងសាទុក្ខដូចគ្នា។ ដូច្នេះ ខ្ញុំគិតថា ព្រះរាជអាជ្ញា -- ខ្ញុំមិនដឹងថាតើខ្ញុំគួរយកពាក្យអីមកនិយាយនោះទេ ខ្ញុំរកនឹកមិនឃើញ។ ពេលខ្លះខ្ញុំគិតថាភាសាអង់គ្លេសពិបាកនិយាយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងយល់អំពីបញ្ហានេះ។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណ។

[០៩:៥១:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់របស់ភាគីដែលបានលើកឡើង ហើយបញ្ហាដែលបានលើកឡើង ដោយភាគីមេធាវីកាពារក្តីអំពីកាលវេលាសុំផ្អាកសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ដោយត្រៀមរៀបចំសម្រាប់ខ្លួនសម្រាប់ដំណើរការសវនាការលើបណ្តឹងសាទុក្ខនោះ ឬក៏កិច្ចដំណើរការនានានៅចំពោះមុខតុលាការកំពូលនោះ អង្គជំនុំជម្រះនឹងយកទៅពិភាក្សា ពិចារណា ហើយនិងជម្រាបជូនដល់ភាគីជ្រាបតាមរយៈអ៊ីម៉ែលរបស់អ្នកច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង។

ហើយឯកាលវិភាគសវនាការបន្តទៅទៀតហ្នឹង អង្គជំនុំជម្រះក៏ដូចគ្នា គឺនឹងជូនដំណឹងទៅភាគីពាក់ព័ន្ធតាមរយៈអ៊ីម៉ែលរបស់មន្ត្រីជាន់ខ្ពស់ ច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងនាពេលបន្ទាប់នេះ ហើយឲ្យបានឆាប់ៗបំផុតមុនពេលបុណ្យភ្ជុំបិណ្ឌ សូមភាគីជ្រាប។

ហើយកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះគឺចប់ត្រឹមនេះហើយ អង្គជំនុំជម្រះមិនអាចធ្វើសវនាការតាមកាលវិភាគដែលបានគ្រោងទុកបានទេ ដូចអង្គជំនុំជម្រះជម្រាបជូនអ៊ីចឹង។

ហើយអង្គជំនុំជម្រះនឹងលើកសវនាការទៅពេលក្រោយ ដោយមិនទាន់បានកំណត់ពេលច្បាស់លាស់ទេ ហើយគឺទៅធ្វើនៅក្រោយបុណ្យភ្ជុំបិណ្ឌ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ឯចំណែកពេលវេលាដែលកំណត់កាលបរិច្ឆេទធ្វើសវនាការពេលណា អង្គជំនុំជម្រះនឹងបង្គាប់ឲ្យនាំយកជនជាប់ចោទទាំងពីររូបមកចូលរួមសវនាការសាជាថ្មី។

បាទ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ០៩:៥៤នាទី)*